**ព្រះរាជាណាចក្រកម្ពុជា**
KINGDOM OF CAMBODIA
**ជាតិ សាសនា ព្រះមហាក្សត្រ**
NATION RELIGION KING

**ក្រសួងការពារជាតិ**
Ministry of National Defense

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ សីហា ឆ្នាំ២០២០

**សូមផ្ញើជូន**

**ឯកឧត្តម នាយឧត្តមសេនីយ៍ ង៉ូ ស៊ានលិច្យ** (Ngo Xuan Lich)

**រដ្ឋមន្ត្រីក្រសួងការពារប្រទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម**

"រដ្ឋធានីហាណូយ"

**ឯកឧត្តមជាទីរាប់អាន**!

ខ្ញុំមានសេចក្តីក្តុកក្តួលដ៏ក្រៃលែងដោយបានទទួលដំណឹងពីការទទួលអនិច្ចកម្មរបស់ឯកឧត្តម **ឡេី ខាភៀវ** (Le Kha Pieu) អតីតអគ្គលេខាមជ្ឈិមបក្ស នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តវៀតណាម កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ ។

មរណភាពរបស់ឯកឧត្តម **ឡេី ខាភៀវ** គឺជាការបាត់បង់ដ៏ធំធេងនូវថ្នាក់ដឹកនាំដ៏ឈ្លៀសវៃ និងយុទ្ធសាស្ត្រមួយរូបដែលបានចូលរួមធ្វើពលិកម្មធ្វើបដិវត្តពោរពេញដោយភាពលះបង់អង់អាចក្លាហានក្នុងការតស៊ូដើម្បីទាមទារឯករាជ្យ និងសុខសន្តិភាព សម្រាប់ប្រជាជន និងប្រទេសវៀតណាម ។ ឯកឧត្តម **ឡេី ខាភៀវ** ក៏ជាយុទ្ធមិត្តដ៏យូរអង្វែងរបស់កម្ពុជា ដោយបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ចំណងមិត្តភាព កិច្ចសហប្រតិបត្តិការដ៏ស្និតល្អួតរវាង កងទ័ព យើងទាំងពីរផងដែរ។

ក្នុងឱកាសដ៏ក្រៀមក្រំនេះ តាងនាមនាយទាហាននៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវសមានចិត្តដ៏ជ្រាលជ្រៅ និងចូលរួមរំលែកមរណៈទុក្ខដ៏ក្រៀមក្រំបំផុតជូនចំពោះឯកឧត្តម និងនាយទាហានទាំងអស់នៃកងទ័ពប្រជាជនវៀតណាម ជាពិសេសក្រុមគ្រួសាររបស់ឯកឧត្តម **ឡេី ខាភៀវ** ចំពោះការបាត់បង់ដ៏ធំធេង និងសោកសៅនេះ។

សូម ឯកឧត្តម នាយឧត្តមសេនីយ៍ រដ្ឋមន្ត្រីក្រសួងការពារប្រទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាមទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រ និងសូមជូនពរឯកឧត្តម ឱ្យបានប្រកបដោយសុខភាពល្អបរិបូណ៌ និងទទួលជោគជ័យគ្រប់ភារកិច្ចដ៏ឧដុង្គឧត្តម ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**
**នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចពិជ័យសេនា ទៀ បាញ់**

George Dimitrov Street, Sangkat Mittapheap, Khan 7Makara, Phnom Penh, Cambodia. Tel/Fax: (855) 023 883 274 Email: generalsec@mod.gov.kh